ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃព្រហស្បតិ៍ ១៥រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០*
*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៦*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៣៣ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ៥២៥លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា

កាលពីខែកក្កដា ឆ្នាំ២០២៦ កន្លងទៅនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (អ.គ.វ.រ.ខ.) បានសម្រេចអនុម័តចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន៣៣គម្រោង ដែលមានទុនវិនិយោគសរុបប្រមាណ៥២៥លានដុល្លារអាម៉េរិក និងអាចបង្កើតឱកាសការងារជូនប្រជាពលរដ្ឋបានប្រមាណ១៧ពាន់កន្លែង។ ក្នុងចំណោមគម្រោងវិនិយោគខាងលើ គម្រោងដែលត្រូវបានចុះបញ្ជីដោយ ក.អ.ក. មានចំនួន២៣គម្រោង ក្នុងទំហំទុនវិនិយោគប្រមាណ៤៩៤លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ៩ពាន់កន្លែង។ ដោយឡែក គម្រោងវិនិយោគដែលត្រូវបានចុះបញ្ជីដោយ អ.គ.វ.រ.ខ. មានចំនួន១០គម្រោង ក្នុងទំហំទុនវិនិយោគប្រមាណ៣១លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ៨ពាន់កន្លែង។ ជាការកត់សម្គាល់ ការវិនិយោគក្នុងរយៈពេល៧ខែដំបូងនៃឆ្នាំ២០២៦នេះ កម្ពុជានៅតែបន្តទាក់ទាញគម្រោងវិនិយោគដែលមានគុណភាព ជាពិសេសក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍ដែលមានកំណើនទំហំទុនវិនិយោគ ខណៈវិស័យឧស្សាហកម្មនៅតែជាវិស័យនាំមុខក្នុងការទាក់ទាញវិនិយោគ។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំខែកក្កដា រួមមាន៖

### ក.ក្រៅតំបន់សេដ្ឋកិច្ចពិសេស

**កសិកម្ម និង កសិ-ឧស្សាហកម្ម**

**គម្រោងវិនិយោគបង្កើតបង្កើតកសិដ្ឋានចិញ្ចឹមត្រី ត្រំ និងសាងសង់រោងចក្រកែច្នៃគុជខ្យង-ត្រី**

- **ទីតាំង៖** ស្រុកស្ទោង ខេត្តកំពង់ធំ
- **ទុនវិនិយោគប្រមាណ៖** ៤១លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ២.៩៣៩កន្លែង។

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគអាជីវកម្មរ៉ែមាស និងសាងសង់រោងចក្រកែច្នៃ**<br>- **ទីតាំង៖** ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសណ្ដាន់ ខេត្តកំពង់ធំ<br>- **ទុនវិនិយោគប្រមាណ៖** ៣១លានដុល្លារអាមេរិក<br>- **បង្កើតការងារ៖** ៤០០កន្លែង។ |
| ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ | **គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយប្រព័ន្ធអាគុយស្តុកទុកថាមពលអានុភាព ៥០០ មេហ្គាវ៉ាត់ / ១០០០មេហ្គាវ៉ាត់ម៉ោង**<br>- **ទីតាំង៖** ស្រុកក្រគរ ខេត្តពោធិ៍សាត់<br>- **ទុនវិនិយោគប្រមាណ៖** ២៤៤លានដុល្លារអាមេរិក<br>- **បង្កើតការងារ៖** ៩កន្លែង។<br><br>**គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់**<br>- **ទីតាំង៖** ស្រុកក្រគរ ខេត្តពោធិ៍សាត់<br>- **ទុនវិនិយោគប្រមាណ៖** ៦២លានដុល្លារអាមេរិក<br>- **បង្កើតការងារ៖** ២៦កន្លែង។ |

**ខ.ក្នុងតំបន់សេដ្ឋកិច្ចពិសេស**

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រកែច្នៃរ៉ែលោហៈមិនមែនជាដែក**<br>- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស កោះកុង ចេជាង<br>- **ទុនវិនិយោគប្រមាណ៖** ១៥លានដុល្លារអាមេរិក<br>- **បង្កើតការងារ៖** ២០០កន្លែង។ |

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែកក្កដា ឆ្នាំ២០២៦

## ដែលត្រូវបានអនុម័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**គម្រោងវិនិយោគ**
**៣៣**
គម្រោង

**ទុនវិនិយោគ**
**៥២៥**
លានដុល្លារអាមេរិក

**បង្កើតការងារ**
**~១៧ពាន់**
កន្លែង

### ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាមេរិក)



**៤១ លាន**
កសិកម្ម និង
កសិ-ឧស្សាហកម្ម

**៣០៦ លាន**
ហេដ្ឋារចនាសម្ព័ន្ធ
និងផ្សេងៗ

**១៧៨ លាន**
ឧស្សាហកម្ម

### ប្រភពទុនវិនិយោគឈានមុខ




### របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ៧+
- ៤-៦
- ១-៣
- មិនមាន